**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

លេខ: ១៥២ សហវ.ប្រក

# ប្រកាស

**ស្តីពីការផ្ទេរការិយាល័យគ្រប់គ្រងថវិការបស់ខេត្ត-ក្រុង និង ការិយាល័យគ្រប់គ្រងថវិកាមន្ទីរជំនាញខេត្ត-ក្រុង នៃនាយកដ្ឋានថវិកាវិនិយោគ និង ហិរញ្ញកិច្ចអោយនៅចំណុះក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ។**

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស រកត ១២៩៨ ៨៨ ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ ... ឥស្សរជនជាអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/៩៤/០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៦ អ.ន.ក្រ/បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋាន ហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ តម្រូវការចាំបាច់នៃការងាររបស់ក្រសួង

## សម្រេច

ប្រការ ១ : ត្រូវបានផ្ទេរការិយាល័យគ្រប់គ្រងថវិការបស់ខេត្ត-ក្រុង និងការិយាល័យគ្រប់គ្រងថវិកាមន្ទីរជំនាញខេត្ត-ក្រុង នៃនាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច អោយទៅនៅចំណុះក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ។

ប្រការ ២ : មន្ត្រីរាជការ និងសំភារៈបច្ចេកទេស ដែលបំរើការងារនៅក្នុងការិយាល័យគ្រប់គ្រងថវិការបស់ខេត្ត-ក្រុង និង ការិយាល័យគ្រប់គ្រងថវិកាមន្ទីរជំនាញខេត្ត-ក្រុង នៃនាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ត្រូវផ្ទេរអោយទៅស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ។

ប្រការ ៣ : ប្រកាសទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៤ : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាព ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី.០៤..ខែមេសាឆ្នាំ២០០៣

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីជាពត៌មាន
- ឯកសារ និង កាលប្បវត្តិ